ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

ក្រសួងពាណិជ្ជកម្ម

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: *ពិសេសអន្តរស្ថាប័ន*

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No: 275
Date: 29.06.11 Time: 9:30
For: GMAC

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការគ្រប់គ្រងកិច្ចសន្យាជួលផលិតបន្ត (Sub-contract) ក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
### រដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសារាចរណែនាំលេខ ០៦ សរណន ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍គម្រោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងវិស័យវាយនភ័ណ្ឌ និងសម្លៀកបំពាក់
- យោងតាមស្ថានការណ៍ចាំបាច់របស់ទីផ្សារផលិតផលសម្លៀកបំពាក់ និងស្បែកជើង

# ស ម្រេ ច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួង រវាងក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **សុខ សុភ័ក្ត្រ** អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ប្រធាន

២- ឯកឧត្តម **សេង សក្ដា** អគ្គនាយក នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៣- លោក **ផាន់ សុផល** អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ អនុប្រធាន

៤- ឯកឧត្តម **មាន សុគតា** ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សមាជិកអចិន្ត្រៃយ៍

៥- ឯកឧត្តម **ខាំ រតនសារ** ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម សមាជិក

៦- លោក **គីម មាសសុខសីហា** ប្រធាននាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់នៃអគ្គនាយកដ្ឋានកាំកុងត្រូល សមាជិក

៧- លោក **ខ៊ុយ រិទ្ធ** អនុប្រធាននាយកដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៨- លោក **ហូ ស៊ីវយ៉ុង** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគីនៃក្រសួងពាណិជ្ជកម្ម សមាជិក

៩- លោកស្រី **គង់ សិទ្ធីកា** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគីនៃក្រសួងពាណិជ្ជកម្ម សមាជិក

១០- លោក **គង់ រុន** នាយកការិយាល័យនៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ សមាជិក

១១- លោក **ទិន ឬស្ស** ប្រធានការិយាល័យ ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២:** គណៈកម្មការនេះមានភារកិច្ច ដូចខាងក្រោម :

- តាមដាន និងជំរុញការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ទាក់ទងទៅនឹងលក្ខខណ្ឌការងារល្អប្រសើរក្នុងវិស័យសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង ។
- ស្រាវជ្រាវ អប់រំ និងណែនាំដល់មូលដ្ឋានឱ្យអនុវត្តកិច្ចសន្យាជួលផលិតបន្ត (Sub-Contract) ឱ្យសមស្របទៅតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានច្បាប់ការងារអន្តរជាតិ ។
- ស្រាវជ្រាវរកអ្នកទទួលកិច្ចសន្យាផលិតបន្តដែលមិនចុះបញ្ជី ការប្រើប្រាស់ពលកម្មមិនស្អាតស្អំ ព្រមទាំងពិនិត្យរបាយការណ៍របស់លេខាធិការដ្ឋាន និង ដាក់ចេញនូវវិធានការណ៍ចាំបាច់នានាសំដៅឱ្យអ្នកទទួលកិច្ចសន្យាជួលផលិតបន្តរបស់រោងចក្រសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង អនុវត្តទៅតាមបទបញ្ញត្តិជាធរមានបានល្អប្រសើរ ។
- ណែនាំ និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជនអំពីគោលនយោបាយជំរុញការនាំចេញ . ច្បាប់ជាតិ និងអន្តរជាតិ ទាក់ទងនឹងការប្រើប្រាស់ពលកម្មមិនស្អាតស្អំ ។
- លើកវិធានការណ៍ ស្នើសុំការណែនាំពីថ្នាក់ដឹកនាំក្រសួងដើម្បីសុំការសម្រេចពីរាជរដ្ឋាភិបាលដើម្បីបង្កា និងលុបបំបាត់ការប្រើប្រាសពលកម្មមិនស្អាតស្អំ ។
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ៣:** បង្កើតលេខាធិការដ្ឋានដែលមានទីតាំងនៅក្នុងក្រសួងពាណិជ្ជកម្ម សម្រាប់ជួយការងារដល់គណៈកម្មការ ។ លេខាធិការដ្ឋានមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **មាន សុគតា** ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាន

២- លោក **ឃឹម ផល្លី** អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សមាជិក

៣- លោក **ខាំ សុវណ្ណ** អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សមាជិក

៤- លោក **សំ សេរីវុទ្ធោ** អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សមាជិក

៥- លោក **មាន ចំណាប់** ប្រធានការិយាល័យនៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សមាជិក

លេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម :

- រៀបចំឯកសារនានាសំរាប់ដាក់ជូនគណៈកម្មការពិនិត្យ និងសំរេច ។
- ស្រាវជ្រាវ និងចងក្រងស្ថិតិនៃបណ្តារោងចក្រសហគ្រាសកាត់ដេរសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង ព្រមទាំងអ្នកទទួលកិច្ចសន្យាផលិតបន្តដែលមិនចុះបញ្ជី ដើម្បីដាក់ជូនគណៈកម្មការពិនិត្យ និងចាត់វិធានការណ៍ ។
- លើកផែនការ និងទទួលយកទៅអនុវត្តនូវវិធានការណ៍ដែលដាក់ចុះដោយគណៈកម្មការ ។
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤:** គណៈកម្មការនេះត្រូវជួបប្រជុំជាទៀងទាត់រៀងរាល់ ០៣ ខែម្តង និងជួបប្រជុំតាមការចាំបាច់ដែលស្នើឡើងដោយលេខាធិការដ្ឋាន ។

**ប្រការ ៥:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦:** អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដូចប្រការ១ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន :**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- សមាគមកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា
- គ្រប់តំបន់សេដ្ឋកិច្ចពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា
- គ្រប់រោងចក្រផលិតសម្លៀកបំពាក់ និង ស្បែកជើង

" ដើម្បីសហការអនុវត្តន៍ "

- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ